# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :៥៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ
## (ផ្នែកA)

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-អភិវឌ្ឍន៍កម្ពុជា

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកែសម្រួលលើមាត្រា ៤ ចំណុច ៤.១ និងចំណុច ៤.៣ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## **សម្រេច**

**មាត្រា១** : បង្កើត **តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ** ( SIHANOUKVILLE S E Z ) ដែលមានទីតាំងស្ថិតនៅភូមិពូធឿង សង្កាត់បិតត្រាំង និងភូមិស្ទាចដែង សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។

**មាត្រា២** : **តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ** ផ្នែក A មានទំហំ ដប់មួយលាន មួយរយសាម សិបប្រាំបួនពាន់ប្រាំមួយរយ ម៉ែត្រក្រឡា ដូចមានប្លង់ទីតាំង ព្រំប្រទល់ ភូមិសាស្ត្រ ក្នុងឧបសម្ព័ន្ធដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣** : ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤** : ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទបញ្ញត្តិ នានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលក្រុងព្រះសីហនុ និងក្រុមហ៊ុន សីហានុវិល ស្ពេសល អ៊ីខនមើមី ហ្សូន ខូអិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ៣ ឆ្នាំ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសូមចុះហត្ថលេខា

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តា**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ